332(1)
SC

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ: ២៦៦
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលដីកា
លេខ: ២១៥ "ក"
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ខឹម | គេច | ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| ២-លោក | ទី | ណេង | ជាចៅក្រម |
| ៣-លោក | សាលី | ធារ៉ា | ជាចៅក្រម |
| ៤-លោក | អឿង | សៀង | ជាចៅក្រម |
| ៥-លោក | គង់ | តារាឆាត | ជាចៅក្រម |

**ចៅក្រមទទួលបញ្ជា**

លោក អឿង សៀង

**ក្រឡាបញ្ជី**

លោក ស៊ិន ភារៈ

**តំណាងមហាអយ្យការ**

ឯកឧត្តម អ៊ុក គីមសិទ្ធិ ជាអគ្គព្រះរាជអាជ្ញារង

**ដើមចោទ (ដើមបណ្តឹងសាទុក្ខ)**

ឈ្មោះ ផ ភេទស្រី អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ អាសយដ្ឋានបច្ចុប្បន្ន ភូមិ ខេត្តព្រៃវែង។

**អ្នកតំណាងដោយអាណត្តិ៖** លោកស្រីមេធាវី គីម ធីតា

**ចុងចម្លើយ (ចុងបណ្តឹងសាទុក្ខ)**

ឈ្មោះ ប ភេទស្រី អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ អាសយដ្ឋានបច្ចុប្បន្ន ភូមិ ខេត្តព្រៃវែង។

**កម្មវត្ថុនៃបណ្តឹង៖** ខ្លឹមសារទាមទារសាលក្រមដែលដើមចោទទាមទារ៖



សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។

១. ទាមទារប្រាក់ជំពាក់ចងការចំនួន ១៧.០០០.០០០(ដប់ប្រាំពីរលាន)រៀល។

២. ទាមទារការប្រាក់ចំនួន ៣% (បីភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃសងការប្រាក់គ្រប់ចំនួន។

៣. ទាមទារសោហ៊ុយខាតបង់ពេលវេលាចំនួន ៤.០០០.០០០(បួនលាន)រៀល។

៤. ទាមទារប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## អំពីអង្គហេតុ និង ចំណុចវិវាទ

### ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:

នៅក្នុងឆ្នាំ២០១៧ ឈ្មោះ ប បានមកហៅឈ្មោះ ដ ឱ្យទៅធានាខ្ចីប្រាក់ពីឈ្មោះ ●១ នៅភូមិ ខេត្តព្រៃវែង ចំនួន ១៧.០០០.០០០ (ដប់ប្រាំពីរលាន) រៀល ខ្ចីក្នុងរយៈពេល ១២ខែ ដោយនិយាយផ្ទាល់មាត់ថា ឱ្យការប្រាក់ ៣% ក្នុងមួយខែ គិតជាការប្រាក់ចំនួន ៥១០.០០០រៀល ហើយបានធ្វើកិច្ចសន្យា ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧ ជាមួយឈ្មោះ ●១ ដោយបានដាក់ដីភូមិ ០១កន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ សន្លឹកផែនទីលេខ លេខក្បាលដី ទំហំ ១០៤៧ ម៉ែត្រការ៉េ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ថែមទៀត។ ចាប់ពីថ្ងៃខ្ចីមក ឈ្មោះ ប បានឱ្យការប្រាក់ទៅឈ្មោះ ដ ជាអ្នកធានាបានតែ ៣ខែ ប៉ុណ្ណោះ គឺឈប់សងទាំងការទាំងដើម ចំណែកដើមចោទជាអ្នកធានា បានបង់ការប្រាក់ជំនួសឱ្យចុងចម្លើយជារៀងរាល់ខែរហូតមក ហើយចុងចម្លើយបដិសេធ មិនសងប្រាក់ទាំងដើមទាំងការទៅឱ្យម្ចាស់បំណុល និងអ្នកធានាឡើយ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រៃវែង សម្រេច:**

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ប សងប្រាក់ដើមចំនួន ១៧.០០០.០០០(ដប់ប្រាំពីរលាន)រៀល និងអត្រាការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំលើប្រាក់ដើម គិតចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ចំនួនទៅដើមចោទឈ្មោះ ដ ។

២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ប សងសោហ៊ុយខាតបង់ពេលវេលាជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន)រៀល ទៅដើមចោទឈ្មោះ ដ ។ ការទាមទារលើសពីនេះ ច្រានចោល។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ តាមមាត្រា ៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃចន្ទ ១រោច ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោងដប់បួន ចំពោះមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃពុធ ៣កើត ខែភទ្របទ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោងដប់បួន ចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ តែចាត់ទុកដូចជាចំពោះមុខ។

-ទុកសិទ្ធិឱ្យភាគីប្តឹងតវ៉ាតាមកំណត់ច្បាប់ ដោយគិតចាប់ពីថ្ងៃបានទទួលលិខិតសាលក្រមតាមមាត្រា ២៦៤

នៃក្រមនីតិវិធីរដ្ឋប្បវេណី។

*សាលក្រមនេះត្រូវបានឈ្មោះ ប ប្ដឹងឧទ្ធរណ៍ តាមបណ្ដឹងលេខ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ សម្រេច ÷**

១. លុបចោលសាលក្រមលេខ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រៃវែង។

២. ច្រានចោលពាក្យបណ្ដឹង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ របស់ដើមចោទឈ្មោះ ជ ។

៣. ប្រាក់ប្រដាប់ជាបន្ទុករបស់ដើមចោទ។

-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩។

បើកសិទ្ធិប្ដឹងសាទុក្ខរយៈពេល ០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះត្រូវបានឈ្មោះ ជ ប្ដឹងសាទុក្ខ តាមបណ្ដឹងលេខ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រង់ចំណុចទាំងមូល នៃសាលដីកា។*

**ខ-អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី**

ឈ្មោះ ប ធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួនបានទាក់ទងដើមចោទដើម្បីខ្ចីប្រាក់ តែគាត់អត់មានប្រាក់ទេ ដោយបាននាំខ្លួនទៅខ្ចីគេបន្ត ដោយបានដាក់ប្លង់បញ្ចាំ ហើយបានធ្វើកិច្ចសន្យា តែពុំទាន់បានទទួលប្រាក់ទេ។ ប្លង់ផ្ទះដាក់ធានា ជាប្លង់របស់បង ●២ ។ ខ្លួនទៅសួរម្ចាស់បំណុលរហូត តែគាត់ថាម្ដងថ្ងៃនេះ ម្ដងថ្ងៃនោះ ហើយមិនបានឱ្យប្រាក់ខ្លួនរហូត។

លោកស្រី ពឹង ធីតា មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ជ ធ្វើសេចក្ដីថ្លែងការណ៍ថា៖ ចុងចម្លើយទៅខ្ចីប្រាក់ពីម្ចាស់បំណុលឈ្មោះ ●១ ដោយបានដាក់បញ្ចាំប្លង់។ កូនក្ដីខ្លួនជាអ្នកដឹងឮ និងជាអ្នកធានា ដូចមានលិខិតខ្ចីប្រាក់ក្នុងសំណុំរឿងស្រាប់។ គាត់បង់ការប្រាក់បានតែពីរខែ ក៏ឈប់បង់រហូត ។ ដោយកូនក្ដីខ្លួនជាអ្នកធានា ទើបគេមកទារប្រាក់ពីគាត់ ហើយកូនក្ដីខ្លួនបានសងទៅម្ចាស់បំណុលគ្រប់ចំនួន ហើយក៏បានដាក់ពាក្យបណ្ដឹងទាមទារប្រាក់ដែលគាត់បានសងទៅម្ចាស់បំណុល ហើយតុលាការបានសម្រេចឱ្យបង់ការប្រាក់ ១៨% ក្នុងមួយឆ្នាំ ទើបកូនក្ដីខ្លួនមិនសុខចិត្តប្ដឹងសាទុក្ខមកនេះ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា
- ក្រោយពីបានស្ដាប់យោបល់របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគីចុងចម្លើយ និងសេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិឱ្យភាគីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។

## តុលាការកំពូល

១. យល់ឃើញថា បណ្តឹងសាទុក្ខលេខ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ឈ្មោះ ដ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៨៣ មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. យល់ឃើញថា ការដែលអវត្តមានភាគីដើមចោទឈ្មោះ ដ នៅពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការកំពូលអាចជំនុំជម្រះបាន ពីព្រោះថា ភាគីនេះបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមកតុលាការតាមការកំណត់ហើយ។អ្នកតំណាងដោយអាណត្តិរបស់សាមីខ្លួនក៏មានវត្តមាននាពេលនេះដែរ។ ម្យ៉ាងទៀត តុលាការកំពូលលើកទីមួយវិនិច្ឆ័យតែអង្គច្បាប់ប៉ុណ្ណោះ តាមមាត្រា ២៨៤ មាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ តុលាការកំពូលបន្តនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន។

៣. យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយលុបចោលសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តព្រៃវែងចោលជាអសារបង់ និងច្រានចោលបណ្តឹង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ របស់ដើមចោទឈ្មោះ ដ ដោយសំអាងថា ដើមចោទឈ្មោះ ដ ពុំមានភស្តុតាងណាមួយឲ្យក្រុមប្រឹក្សាជំនុំជម្រះអាចពិនិត្យពិចារណាស្របតាមមាត្រា ១២៣ នៃក្រមរដ្ឋប្បវេណី និងការអះអាងរបស់ចុងចម្លើយថា ក្រោយពីបានធ្វើឯកសារផ្តិតមេដៃសព្វគ្រប់មក ខ្លួនមិនបានទទួលប្រាក់ពីដើមចោទទេ ហើយថា ការអះអាងរបស់ចុងចម្លើយនេះ ស៊ីសង្វាក់នឹងការអះអាងរបស់ដើមចោទប្រែប្រួលនៅសាលាដំបូងថា ចុងចម្លើយបានខ្ចីប្រាក់សរុបចំនួន ៥លើក លើកចុងក្រោយខ្ចីបន្ថែមគម្រប់ចំនួន ១៧.០០០.០០០(ដប់ប្រាំពីរលាន)រៀល នៅសាលាឧទ្ធរណ៍ដើមចោទបែរជាអះអាងថា ចុងចម្លើយបានខ្ចីប្រាក់ចំនួនពីរដំណាក់កាល លើកទី១ ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល លើកទី២ ចំនួន ១២.០០០.០០០(ដប់ពីរលាន)រៀលវិញ ។ ការយល់ឃើញរបស់សាលាឧទ្ធរណ៍ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់ទេ ពីព្រោះមិនបានពិចារណាពីមូលដ្ឋានភស្តុតាងដូចជា៖

ក. កិច្ចសន្យា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ដែលជាច្បាប់របស់គូភាគី ដែលភាគីចុងចម្លើយទទួលស្គាល់ថា បានផ្តិតមេដៃត្រឹមត្រូវ។

ខ. ចម្លើយរបស់ម្ចាស់ប្រាក់ឈ្មោះ ●១ ដែលបានឆ្លើយឱ្យការនៅនីតិវិធីតុលាការ។

គ.តើមានភស្តុតាងអ្វីបន្ថែមដែលបញ្ជាក់ថា ចុងចម្លើយមិនបានទទួលប្រាក់នៅពេលផ្តិតមេដៃលើកិច្ចសន្យា។

យោងតាមសំអាងហេតុខាងលើ គប្បីសម្រេចបញ្ជូនសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីវិនិច្ឆ័យសេចក្តីឡើងវិញ។

៤. យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ **ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩** របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវទេ។

៥. យល់ឃើញថា តាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីត្រូវជាបន្ទុករបស់ចុងចម្លើយឈ្មោះ ប ។

សម្គាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១. ទទួលបណ្តឹងសាទុក្ខលេខ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ឈ្មោះ ដ ។

២. បដិសេធសាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

៣. បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ។

៤. ប្រាក់ប្រដាប់ក្តីនៅថ្នាក់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយឈ្មោះ ប ។

សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០ ។

| | | | |
|---|---|---|---|
| ឯកឧត្តម | **ជីវ** | **កេច** | ប្រធាន |
| លោក | ទី | ណេង | ចៅក្រម |
| លោក | សាលី | ធារ៉ា | ចៅក្រម |
| លោក | អឿង | សៀង | ចៅក្រម |
| លោក | គង់ | តារាផាត | ចៅក្រម |
| លោក | ស៊ិន | ភារៈ | ក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃចន្ទ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
ស៊ិន_ភារៈ

**បានឃើញ**
ថ្ងៃចន្ទ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ជីវ កេច